ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC)

កិច្ចប្រជុំលើកទី 27

ថ្ងៃព្រហស្បតិ៍ ទី 13 ខែសីហា ឆ្នាំ 2026

ទីតាំង៖ First Congregational Church, 4 Main Street, Stockbridge, MA 01262
ម៉ោង 6:30 ល្ងាច ដល់ 8:00 យប់

<u>កំណត់ហេតុកិច្ចប្រជុំ</u>

ទីកន្លែងប្រជុំ៖ ដោយផ្ទាល់

ឯកសារកិច្ចប្រជុំ៖ របៀបវារៈ ស្លាយ

សមាជិកក្រុមប្រឹក្សា៖

- María Belén Power - ដោយផ្ទាល់
- Marcos Luna – ដោយផ្ទាល់
- Jen Salinetti - ដោយផ្ទាល់

- Melissa Ferretti - អនឡាញ
- Peter Maathey - អនឡាញ
- Cheryll Holley – អនឡាញ
- Sofia Owen – អនឡាញ
- Caroline Hon – អនឡាញ
- Patricia Spence – អនឡាញ
- Madeline Fraser Cook – អនឡាញ

- Harleen Marwah – អវត្តមាន
- Lydia Lowe – អវត្តមាន
- Paula Garcia – អវត្តមាន
- Miles Gresham - អវត្តមាន

1. **មតិស្វាគមន៍ និងទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ**
   María Belén Power បានស្វាគមន៍អ្នកចូលរួមទាំងអស់។

   Sophia Spungin បានជម្រាបជូនអំពីទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ រួមទាំងការប្រើប្រាស់ប្រអប់សំណួរនិងចម្លើយ (Q&A) និងលទ្ធភាពអាចទទួលបានអ្នកបកប្រែផ្ទាល់មាត់។

2. **ទិដ្ឋភាពទូទៅនៃរបៀបវារៈ**
   María Belén បានរំលឹកឡើងវិញអំពីរបៀបវារៈនៃកិច្ចប្រជុំ។

3. **ការហៅឈ្មោះសមាជិក/ការអនុម័តលើកំណត់ហេតុប្រជុំពីមុន**

María Belén បានធ្វើការហៅឈ្មោះសមាជិកក្រុមប្រឹក្សា EJC។
នៅពេលចាប់ផ្តើមកិច្ចប្រជុំ សមាជិកក្រុមប្រឹក្សាដូចខាងក្រោមមានវត្តមានចូលរួម៖ Madeline Fraser Cook, Melissa Ferretti, Cheryll Holley, Caroline Hon, Marcos Luna, Peter Maathey, Sofia Owen, Jen Salinetti, Patricia Spence

សមាជិកក្រុមប្រឹក្សាដូចខាងក្រោមមិនមានវត្តមានចូលរួម៖ Lydia Lowe, Harleen Marwah, Miles Gresham, Paula Garcia

María Belén បានបើកវេទិកាសម្រាប់
ការស្នើសុំមួយដើម្បីអនុម័តកំណត់ហេតុនៃកិច្ចប្រជុំ EJC លើកទី 26 ថ្ងៃទី 11 ខែមិថុនា ឆ្នាំ 2026។ **Patricia Spence** បានស្នើសុំអនុម័ត។ **Jen Salinetti** បានគាំទ្រសំណើនេះ។ សមាជិកក្រុមប្រឹក្សាជ្រាំមួយរូបបានអនុម័តកំណត់ហេតុ ហើយបួនរូបបានបោះឆ្នោតអនុបវាទ។

4. **វគ្គសំណួរ និងចម្លើយជាសាធារណៈលើកទីមួយ**
អ្នកចូលរួមសាធារណៈតាមប្រព័ន្ធអនឡាញបានផ្តល់យោបល់ និងសំណួរ៖
   - អ្នកចូលរួមម្នាក់មកពី Great Barrington បានចែករំលែកថា ការសាងសង់មជ្ឈមណ្ឌលទិន្នន័យថ្មីៗនៅក្នុងតំបន់ខោនធី Berkshire គឺជាក្តីព្រួយបារម្ភមួយ ដោយសារតែលទ្ធភាពនៃការបំភាយកាបូន (carbon footprint) និងការរំខានដែលអាចកើតមានដល់ទីជម្រកធម្មជាតិ និងសុខភាពមនុស្ស។

មតិយោបល់ពីសំណួរ និងចម្លើយ (Q&A) មានរៀបរាប់ដូចខាងក្រោម

#	មតិយោបល់ និងសំណួរ	ឈ្មោះអ្នកសួរ	ចម្លើយ
1	ទាក់ទងនឹងដំណើរការញត្តិស្តីពីការកំណត់ស្ថានភាព EJ ដែលបានពិភាក្សានៅក្នុងកិច្ចប្រជុំខែមេសា៖ តើលោកអ្នកមានការកំណត់ពេលវេលាសម្រាប់ការបញ្ចប់ដំណើរការនោះដែរឬទេ? តើញត្តិបច្ចុប្បន្ននឹងត្រូវតម្រូវឱ្យដាក់ពាក្យស្នើសុំឡើងវិញដែរឬទេ? តើក្រុមប្រឹក្សាមានសិទ្ធិអំណាចក្នុងការស្វែងរកថាតើមានសហគមន៍ផ្ទះជល់តស្រេច (manufactured home communities) ចំនួនប៉ុន្មានដែលបានបាត់បង់ស្ថានភាព EJ នៅក្នុងដំរឿនឆ្នាំ 2020 ដែរឬទេ? សូមអរគុណទុកជាមុន។	Kristen Mello	María Belén Power បានជម្រាបជូនថា ក្រុមការងារផ្នែកច្បាប់កំពុងបញ្ចប់សេចក្តីព្រាងបទប្បញ្ញត្តិ ហើយគួរតែអាចផ្តល់នូវបទប្បញ្ញត្តិដែលបានធ្វើបច្ចុប្បន្នភាពនៅក្នុង កិច្ចប្រជុំ EJC បន្ទាប់។

5. **បទបង្ហាញស្តីពីមជ្ឈមណ្ឌលទិន្នន័យ**
   វាគ្មិន **Melissa Lavinson នាយកផ្នែកបរិវត្តកម្មថាមពល**
   បានផ្តល់ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌដែលទើបនឹងដាក់ឱ្យប្រើប្រាស់ថ្មី
   ដែលត្រូវបានចេញផ្សាយនៅថ្ងៃទី 25 ខែមិថុនា ឆ្នាំ 2026
   ដើម្បីកំណត់ការរំពឹងទុកយ៉ាងច្បាស់លាស់សម្រាប់ការអភិវឌ្ឍមជ្ឈមណ្ឌលទិន្នន័យ
   ប្រកបដោយការទទួលខុសត្រូវ ក្នុងការណែនាំដល់ទីភ្នាក់ងាររដ្ឋ សាលាក្រុង
   និងអ្នកបង្កើតគោលនយោបាយ។ Melissa Lavinson
   បានផ្តល់ព័ត៌មានផ្ទៃខាងក្រោយអំពីមជ្ឈមណ្ឌលទិន្នន័យ
   ការអភិវឌ្ឍមជ្ឈមណ្ឌលទាំងនោះនៅក្នុងរដ្ឋ Massachusetts
   និងបានរំលឹកឡើងវិញនូវគោលការណ៍ និងដំហានបន្ទាប់នៃក្របខ័ណ្ឌថ្មីនេះ។

   សមាជិកក្រុមប្រឹក្សាបានសាកសួរអំពីយន្តការបទប្បញ្ញត្តិផ្សេងទៀត
   ការស្របគ្នានៃនិយមន័យនៃថាមពលស្អាត
   សមត្ថភាពសម្រាប់មជ្ឈមណ្ឌលទិន្នន័យក្នុងការប្រើប្រាស់ទឹកមិនអាចទទួលទានបាន
   (non-potable water) អត្ថិភាពនៃមជ្ឈមណ្ឌលទិន្នន័យបច្ចុប្បន្ន
   និងក្របខ័ណ្ឌទូលំទូលាយផ្សេងទៀតនៅទូទាំងប្រទេស
   ហើយបានលើកទឹកចិត្តឱ្យធ្វើឱ្យព័ត៌មាន
   ទាក់ទងនឹងការបង្កើតក្របខ័ណ្ឌនេះអាចឱ្យមនុស្សគ្រប់គ្នាទទួលបាន។
   សមាជិកក្រុមប្រឹក្សា Marcos Luna
   បានស្នើសុំការបំភ្លឺអំពីចំនួនមជ្ឈមណ្ឌលទិន្នន័យដែលមាននៅក្នុងរដ្ឋ Massachusetts
   និងប្រតិបត្តិការរបស់មជ្ឈមណ្ឌលទាំងនោះរហូតមកដល់បច្ចុប្បន្ន។ Melissa Lavinson
   នឹងចែករំលែកព័ត៌មាននេះជាមួយសមាជិកក្រុមប្រឹក្សា EJ។

6. **វគ្គសំណួរ និងចម្លើយសាធារណៈលើកទីពីរ**
   អ្នកចូលរួមសាធារណៈតាមប្រព័ន្ធអនឡាញ និងចូលរួមដោយផ្ទាល់
   បានផ្តល់យោបល់និងសំណួរ៖
   - អ្នកចូលរួមម្នាក់បានសាកសួរអំពីទំហំក្រឡាផ្ទៃគិតជាហ្វីតការ៉េនៃមជ្ឈមណ្ឌលទិន្ន
     ន័យដ៏ធំបំផុតបច្ចុប្បន្ននៅក្នុងរដ្ឋ Massachusetts ដែលមានទីតាំងនៅ Boston
     និងលទ្ធភាពក្នុងការកែច្នៃរចនា
     សម្ព័ន្ធដែលមិនសូវត្រូវបានប្រើប្រាស់ឱ្យអស់លទ្ធភាព ដើម្បីដាក់មជ្ឈមណ្ឌល
     ទិន្នន័យ។
   - អ្នកចូលរួមម្នាក់បានសង្កត់ធ្ងន់លើការអនុវត្តតាមក្របខ័ណ្ឌផែនការថាមពលស្អា
     ត និងអាកាសធាតុ MA (MA Clean Energy and Climate Plan Framework)
     ហើយបានសាកសួរអំពីផលប៉ះពាល់ដែលបានព្យាករទុកថា
     មជ្ឈមណ្ឌលទិន្នន័យអាចមានលើវឌ្ឍនភាពនេះ។
   - អ្នកចូលរួមម្នាក់បានសាកសួរអំពីអាជ្ញាធរណាមួយដែលនឹងតាមដានលើក្រុមហ៊ុន
     សេវាសាធារណៈ “ដែលបង្វែរការចំណាយ (cost-shifting)”
     និងថាតើបណ្តាញអគ្គិសនីនឹងត្រូវបាន

ធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ដើម្បីបំពេញតាមគោលដៅនៃការបំភាយឧស្ម័ននាពេលអនាគតដែរឬទេ។

- អ្នកចូលរួមម្នាក់បានសាកសួរអំពីសេចក្តីព្រាងច្បាប់ដែលត្រូវបានលើកឡើងដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើមនីតិកម្មថាមពលកាន់តែទូលំទូលាយ។ Melissa បានចែករំលែកសេចក្តីព្រាងច្បាប់ព្រឹទ្ធសភា MA S3166 និងសេចក្តីព្រាងច្បាប់រដ្ឋសភា H5175។

មតិយោបល់ពីសំណួរ និងចម្លើយ (Q&A) មានរៀបរាប់ដូចខាងក្រោម

#	មតិយោបល់ និងសំណួរ	ឈ្មោះអ្នកសួរ	ចម្លើយ
1	ទីតាំង ទីតាំង ទីតាំង! តើមានការព្រួយបារម្ភណាមួយអំពីការកំណត់ទីកន្លែងដែលមជ្ឈមណ្ឌលទិន្នន័យ (ជាពិសេសមជ្ឈមណ្ឌលទិន្នន័យធំៗ កម្រិត hyper-datacenters) ពិតជាមិនសមស្រប ឬមិនគួរដាក់ទីតាំងនៅទីនោះដែរឬទេ? គ្រាន់តែជាការគិតមួយប៉ុណ្ណោះ!	អនាមិក	Melissa Lavinson បានឆ្លើយតបថា ប្រសិនបើមានមជ្ឈមណ្ឌលទិន្នន័យទំហំធំជាងនេះ ពួកគេត្រូវតែប្រើប្រាស់ប្រភពនៃការបង្កើតថាមពលផ្ទាល់ខ្លួន។ ជាលទ្ធផល ពួកគេត្រូវឆ្លងកាត់ក្រុមប្រឹក្សាជ្រើសរើសទីតាំងកន្លែងផ្តល់ថាមពល (Energy Facilities Siting Board) ដែលបង្កឱ្យមានការវាយតម្លៃភាពសមស្របនៃទីតាំង។ រដ្ឋកំពុងធ្វើការលើឧបករណ៍ប្រើប្រាស់ដីធ្លីដែលមានទំហំធំជាងមុនដើម្បីវាយតម្លៃស្រទាប់ផ្សេងៗទាក់ទងនឹងការប្រើប្រាស់ដីធ្លី។
2	សូមមេត្តាប្រុងប្រយ័ត្នខ្ពស់ក្នុងការស៊ើបអង្កេតបច្ចេកវិទ្យាធ្វើឱ្យត្រជាក់ជុំវិញមជ្ឈមណ្ឌលទិន្នន័យ និងកិច្ចព្រមព្រៀងរបស់ពួកគេជាមួយក្រុមហ៊ុនផលិត PFAS។ ការអភិវឌ្ឍទាំងនេះមិនសមស្របនឹងស្ថិតនៅលើប្រភពទឹកក្រោមដី (aquifers) របស់យើង ឬនៅក្នុងជ្រលងភ្នំដែលព័ទ្ធជុំវិញដោយភ្នំនោះឡើយ។	Kristen Mello	មិនបានឆ្លើយតបទេ។

	ការសម្រេចចិត្តដែលលោកអ្នកធ្វើឡើងនៅពេលនេះ អាចធ្វើឱ្យសហគមន៍ របស់យើងមិនអាចរស់នៅបាន ប្រសិនបើយើងមិនប្រុងប្រយ័ត្នចំពោះផលវិបាកនោះទេ។ https://www.chemours.com/en/news-media-center/all-news/press-releases/2025/chemours-and-datavolt-announce-agreement-to-accelerate-adoption-of-liquid-cooling-solutions		
3	ដោយសារអ្នកអភិវឌ្ឍន៍មជ្ឈមណ្ឌលទិន្នន័យនៅតំបន់ផ្សេងទៀត នៃភាគឦសាន បានទិញរោងចក្រអគ្គិសនី ដំណើរការពេលតម្រូវការឡើងខ្ពស់ (peaking power plants) ជាយុទ្ធសាស្ត្រសម្រាប់ការនាំយក ថាមពលផ្ទាល់ខ្លួន តើរដ្ឋកំពុងប្រឹងប្រែង អ្វីខ្លះដើម្បីការពារកុំឱ្យរោងចក្រ ដែលបង្កការបំពុលខ្លាំងទាំងនេះ បន្តដំណើរការ ជាជាងការកាត់បន្ថយការបញ្ចេញ កាបូន (decarbonizing)?	Brittany Ebeling	Melissa Lavinson បានជម្រាបជូនថា EEA បាននិងកំពុងធ្វើការស្រាវជ្រាវ លើបញ្ហានេះក្នុងរយៈពេល 18 ខែកន្លងមកនេះ ដោយពិនិត្យមើលកន្លែងផ្សេងៗ នៅទូទាំងរដ្ឋ Massachusetts ជាករណីសិក្សា។ EEA កំពុង ស្រាវជ្រាវ គោលនយោបាយទាំងនៅ កម្រិតតំបន់ និងកម្រិតរដ្ឋ ដោយរបាយការណ៍មួយនឹងត្រូវ បានចេញផ្សាយនៅក្នុងខែកញ្ញា ។

7. **ជំហានបន្ទាប់ និងការបិទកិច្ចប្រជុំ**

María Belén បានរំលឹកដល់សមាជិកក្រុមប្រឹក្សាអំពីកិច្ចប្រជុំបន្ទាប់នៅ**ថ្ងៃទី 8** ខែ**តុលា ទីតាំងនឹងត្រូវប្រកាសជូនពេលក្រោយ។**

María Belén បានស្នើសុំសំណើមួយដើម្បីបញ្ចប់កិច្ចប្រជុំ។ **Melissa Ferretti** បានស្នើសុំបញ្ចប់កិច្ចប្រជុំ។ **Sofia Owen** បានគាំទ្រ។ Sophia Spungin បានធ្វើការហៅឈ្មោះ
ហើយសមាជិកក្រុមប្រឹក្សាដែលមានវត្តមានទាំងអស់បានអនុម័ត។
កិច្ចប្រជុំបានបញ្ចប់នៅម៉ោង **7:57 យប់**។